ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៥-០១៧ ៧៧៥ ធ.ផ.ក

# សេចក្តីជូនដំណឹង
## ស្តីពី
## កាលបរិច្ឆេទនៃការចេញផ្សាយមូលបត្រអាចជួញដូរបាន

ក្នុងគោលបំណងគាំទ្រដល់ដំណើរការអនុវត្តគោលនយោបាយរូបិយវត្ថុ និងជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ការគ្រប់គ្រង និងវិនិយោគសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាមានកិត្តិយសសូមជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជ្រាបថា៖

ធនាគារជាតិនៃកម្ពុជានឹងចេញផ្សាយមូលបត្រអាចជួញដូរបាន (NCD) លក់ជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយ (១) លើក ក្នុងមួយសប្តាហ៍ គឺនៅរៀងរាល់ថ្ងៃពុធនៃថ្ងៃធ្វើការនៃសប្តាហ៍នីមួយៗ ហើយនឹងចាប់អនុវត្តពីថ្ងៃពុធ ទី៥ ខែតុលា ឆ្នាំ២០១៦ តទៅ រហូតដល់មានការជូនដំណឹងជាថ្មី។ ធនាគារជាតិនៃកម្ពុជានឹងទទួលពាក្យសុំជាវ NCD ចាប់ ពីម៉ោង៨:០០ ព្រឹក រហូតដល់ម៉ោង១១:០០ ព្រឹក ។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមានបំណងចង់បានព័ត៌មានលម្អិតពាក់ព័ន្ធនឹងការជាវ NCD សូមទាក់ទងនាយកដ្ឋានប្រតិបត្តិការរៀងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ឬ តាមរយៈទូរស័ព្ទលេខ ០២៣៧២២៥៦៣ ext ១០៥៨ ឬតាម E-mail chhin.dina@nbc.org.kh ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោកនាយក/នាយិកា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជ្រាបជាព័ត៌មាន ។ល

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦

**ជ-អគ្គនាយកបច្ចេកទេស**
**អគ្គនាយករង**

**គាំ គណ្ណា**

**កន្លែងទទួល**
- គ្រប់អគ្គនាយកដ្ឋាន "ដើម្បីជូនជ្រាប"
- នាយកដ្ឋានពាក់ព័ន្ធ
- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ "ដើម្បីជ្រាបនិងសហការអនុវត្ត"